អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ អំពីព្រះត្រៃសរណគមន៍

www.hoksavann.org

ថ្ងៃទី១ មេសា ២០១២



ពាក្យថា «ព្រះត្រៃសរណគមន៍» ប្រែថា ការកាន់យកទីរលឹក (ទីពឹង) ៣យ៉ាង បានដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ ពុទ្ធបរិស័ទតែងសូត្ររំលឹកដល់គុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាមុន ទើបបំពេញកិច្ចផ្សេងៗទៀតជាក្រោយ មានសមាទានសីលជាដើម ក្នុងពិធីកម្មរបស់ព្រះពុទ្ធសាសនា ព្រោះថាធម្មតាមុននឹងប្រតិបត្តិធ្វើតាមគ្រូ ឬសាស្ត្រាចារ្យណាមួយ ត្រូវមានជំនឿទៅលើគ្រូ ឬសាស្ត្រាចារ្យនោះជាមុន ។ យ៉ាងណាមិញ មុននឹងប្រតិបត្តិតាមធម៌ព្រះពុទ្ធ តែងតែមានជំនឿទៅលើព្រះពុទ្ធជាមុន ដែលអង្គនៃអ្នកមានជំនឿនោះ ត្រូវប្រកបដោយអង្គបី គឺមានជំនឿទៅលើគុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ (សទ្ធា), ពិចារណាយល់ច្បាស់ (បញ្ញា), ហ៊ានលះបង់ជីវិត មិនលះបង់ជំនឿនេះឡើយ (ជីវិតបរិច្ចាគ) ។ ត្រៃសរណគមន៍នេះ ជួនកាលគេហៅថា ត្រៃរតនៈ ប្រែថាកែវបីយ៉ាង លោកប្រៀបព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដូចជាកែវមណីជោតិដ៏មានតម្លៃ ជាកែវទិព្វចង់ប្រាថ្នាអ្វី នឹងបានសំរេចដូចប្រាថ្នា ។ ការសូត្រនមោនោះ គឺសូត្ររំលឹកដល់គុណព្រះពុទ្ធជាមុន ។ ឯការសូត្រនមោសូត្រដដែលៗរហូតដល់បីដងនោះ គឺរបស់សំខាន់គេតែងថាបីដង ជាការឲ្យតម្លៃខ្លាំងទៅលើព្រះពុទ្ធ ជាអគ្គបុគ្គលដ៏ឧត្តមបំផុតក្នុងលោក ។ ប្រៀបដូចពុទ្ធបរិស័ទទទួលអនុមោទនាត្រេកអរបុណ្យកុសលដែលអ្នកដទៃធ្វើ ថាសាធុរហូតបីដង ជាពាក្យទទួលអំណរខ្លាំង ។ ប្រៀបម៉្យាងទៀត ដូចវេញខ្សែបីផ្លូងទើបជាប់មាំល្អ ។ ឯការសូត្ររំលឹកគុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាគំរប់ពីរដងផង បីដងផង ក៏មានន័យដូចខាងលើនេះដែរ ។

សំនួរថា ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ តើអង្គណាកើតមុននោះ តាមពិតព្រះធម៌ជាច្បាប់ធម្មជាតិ មាននៅជាធម្មតា ទោះបីព្រះពុទ្ធមិនត្រាស់ដឹង ក៏ព្រះធម៌មាននៅជាធម្មតា ប៉ុន្តែគ្មានអ្នកណាដឹងយកមកនិយាយប្រាប់ លុះព្រះពុទ្ធត្រាស់ដឹង ទើបព្រះអង្គជ្រាបហេតុផលដែលហៅថាព្រះធម៌ ហើយសំដែងទើបមនុស្សសត្វបានដឹង ដែលសព្វថ្ងៃមាននៅក្នុងព្រះត្រៃបិដក ។ ដូច្នេះឃើញថា ព្រះពុទ្ធត្រាស់ដឹងតែមួយព្រះអង្គឃើញការពិត គឺព្រះធម៌នេះហើយ មិនចាំបាច់ត្រាស់ដឹងព្រះពុទ្ធទីពីរ ក្នុងពេលជាមួយគ្នាឡើយ ព្រោះបើព្រះពុទ្ធទីពីរត្រាស់ដឹង ក៏ឃើញសច្ចធម៌នេះដូចគ្នា ។ ដូចព្រះពុទ្ធសមណគោត្តមបរិនិព្វាន ហើយគ្រប់៥០០០ឆ្នាំ ធម៌វិន័យរបស់ព្រះអង្គក៏បានបាត់បង់ទៅទៀត ទើបមានអ្នកត្រាស់ដឹងបន្តមកទៀត ដែលហៅថាព្រះសិអារ្យមេត្តេយ្យ (មេត្រី) ។ ព្រះពុទ្ធសព្វញ្ញុតញ្ញាណ អ្នកត្រាស់ដឹងសព្វ ទើបមានសមត្ថភាពសំដែងធម៌ បញ្ញត្តិវិន័យ ទើបកើតមានព្រះសង្ឃ ។ ចំណែកព្រះបច្ចេកពុទ្ធ ប្រែថាអ្នកត្រាស់ដឹងពិសេសតែឯង គ្មានសមត្ថភាពសំដែងធម៌ បញ្ញត្តិវិន័យបានឡើយ ។ បុគ្គលដែលបានស្តាប់ធម៌ពីព្រះពុទ្ធអ្នកត្រាស់ដឹង ហើយប្រតិបត្តិតាមរហូតបានសំរេចធម៌ជាន់ខ្ពស់មគ្គផលនិព្វាន ជាព្រះអរហន្តហៅថាអនុពុទ្ធ ជាសាវករបស់ព្រះពុទ្ធ ។ បើតាមន័យនេះ ព្រះធម៌មាននៅជាធម្មតា ប៉ុន្តែបើគ្មានអ្នកត្រាស់ដឹង ក៏គ្មានអ្នកណាដឹងធម៌នេះដែរ ។ ដូច្នេះហើយបានជាតាមលេខរៀង គេគោរពព្រះពុទ្ធមុន គឺគោរពអ្នករកឃើញធម៌មុន ទើបគោរពព្រះធម៌ដែលព្រះពុទ្ធត្រាស់ដឹង ហើយព្រះអង្គបញ្ញត្តិវិន័យទើបកើតមានព្រះសង្ឃ គោរពព្រះសង្ឃជាទីបី ព្រោះបើព្រះពុទ្ធពុំត្រាស់ដឹង ព្រះធម៌ និងព្រះសង្ឃពុំកើតមានឡើយ ។

ពាក្យថា យកព្រះពុទ្ធជាទីរលឹក បានន័យថា រលឹកពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ហើយយកមកប្រតិបត្តិតាម ។ ពាក្យថា ព្រះពុទ្ធជាទីពឹងមានន័យថា ពឹងព្រះពុទ្ធអ្នកបង្ហាញផ្លូវ ដូចព្រះអង្គបង្ហាញមគ្គប្រកបដោយអង្គ៨ ជាផ្លូវនៃការរំលត់ទុក្ខពោលគឺព្រះនិព្វាន ។ ពាក្យថា យកព្រះធម៌ជាទីពឹងទីរលឹក បានន័យថា ប្រតិបត្តិតាមព្រះធម៌ដែលព្រះពុទ្ធបានសំដែង ។ ពាក្យថា យកព្រះសង្ឃជាទីពឹងទីរលឹក បានន័យថា ជឿថាព្រះសង្ឃជាពិសេសព្រះអរិយសង្ឃ បានប្រតិបត្តិល្អត្រឹមត្រូវពិតមែន ដែលអាចឲ្យខ្លួនធ្វើទានបានផលច្រើន ហើយអាចឲ្យខ្លួនស្តាប់ធម៌ទេសនាពីព្រះសង្ឃដែលតំណាងព្រះពុទ្ធ ។ ការយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹក គឺសិក្សាឲ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ហើយប្រតិបត្តិតាម ពុំមែនបន់ស្រន់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃឲ្យជួយខ្លួនឡើយ ។ ជំនឿមនុស្សជំនាន់ដើម កាលបើមានសេចក្តីទុក្ខកើតឡើង តែងតែបន់ស្រន់បួងសួងវត្ថុស័ក្តិសិទ្ធិដែលគេពុំអាចដឹងថានៅទីណាឲ្យមកជួយខ្លួន ព្រះពុទ្ធសំដែងថា ការទីពឹងបែបនោះ បុគ្គលពុំអាចរួចចាកទុក្ខបានឡើយ ប៉ុន្តែបុគ្គលណាមួយបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹក ហើយប្រតិបត្តិធម៌ ឃើញអរិយសច្ច៤ ទើបបុគ្គលនោះរួចចាកទុក្ខបាន ។ ពុទ្ធភាសិតមួយទៀតពោលថា អត្តទីបា ធម្មទីបា អនញ្ញសរណាវិហរថ ប្រែថា ម្នាលភិក្ខុ ទាំងឡាយ ចូរអ្នកយកខ្លួនជាទីពឹង យកធម៌ជាទីពឹង អ្វីក្រៅពីនោះពុំមែនជាទីពឹងរបស់អ្នករាល់គ្នាឡើយ ។ ពាក្យថា យកខ្លួនជាទីពឹង បានសេចក្តីថា ប្រតិបត្តិធម៌ដោយខ្លួនឯង ។ ពាក្យថា យកធម៌ជាទីពឹង បានសេចក្តីថា ប្រតិបត្តិតាមព្រះធម៌អដ្ឋង្គិកមគ្គដែលព្រះពុទ្ធបានសំដែង ។៚

*　*

*